# I. ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០៦៩៩/០៤

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

## ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា

## ចូលជាសមាជិក

## នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី

**មាត្រា ១.-** អនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីការបង្កើតទីភ្នាក់ងារធានាការវិនិយោគពហុភាគី ដែលមានអត្ថបទភ្ជាប់មកជាមួយ និងយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ ។

**មាត្រា ២.-** អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទិញភាគហ៊ុនរបស់ទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ ជាទឹកប្រាក់ចំនួនបួនរយសាមសិបពាន់ (៤៣០.០០០) អេស.ឌី.អ័រ ដោយអនុវត្តទៅតាមបែបបទ ដែលកំណត់ក្នុងអនុសញ្ញា ស្តីពីការបង្កើតទីភ្នាក់ងារនេះ ។

**មាត្រា ៣.-** រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តនីតិវិធីទាំងឡាយ ដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជា ជាសមាជិកនៃទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ ។

**មាត្រា ៤.-** ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានទូលបង្គំថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់